**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ...០៣៦...សណន.សក.ដជទ

# សេចក្តីណែនាំ
# ស្តីពី
# បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវទឹក នៅរដ្ឋបាលរាជធានី ខេត្ត

ក្នុងគោលបំណងបង្វិតសេវាសាធារណៈឲ្យកៀកប្រជាពលរដ្ឋ សំដៅធ្វើឲ្យការផ្តល់សេវាមានប្រសិទ្ធភាព តម្លាភាព និងរហ័សទាន់ចិត្ត រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសាធារណការនិងដឹកជញ្ជូនបានធ្វើប្រតិភូកម្មសេវាសាធារណៈជាច្រើនក្នុងវិស័យដឹកជញ្ជូន ក្នុងនោះវិស័យដឹកជញ្ជូនផ្លូវទឹកមានសេវាសាធារណៈចំនួន៣រួមមាន៖ ១.ការផ្តល់បណ្ណសម្គាល់ជលយាន ២.ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន និង៣.ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក។ ទន្ទឹមនឹងនេះដែរ តាមរយៈអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និងអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ការផ្តល់សេវារដ្ឋបាលលើការគ្រប់គ្រង និងការផ្តល់លិខិតអនុញ្ញាតជចម្លងដែលជាប្រភេទសេវាមួយនៅក្នុងចង្កោមសេវាផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់មុខងារនេះជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ដើម្បីធានាប្រសិទ្ធភាពដល់ការផ្តល់សេវារដ្ឋបាលក្នុងវិស័យដឹកជញ្ជូនផ្លូវទឹកនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំដូចខាងក្រោម៖

## ១.ការផ្តល់បណ្ណសម្គាល់ជលយាន

អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ត្រូវផ្តល់សេវាបណ្ណសម្គាល់ជលយាន ការស្នើសុំប្តូរម៉ាស៊ីន ពណ៌ កែមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន និងការប្តូរ (ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន ដែលបាននិងកំពុងចរាចរលើផ្លូវទឹកក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.១.ការផ្តល់បណ្ណសម្គាល់ជលយាន (ចំណុះផ្ទុកពី៤០តោនចុះក្រោម ផ្ទុកអ្នកដំណើរពី៥០នាក់ចុះក្រោម កម្លាំងម៉ាស៊ីនពី៩០សេះចុះក្រោម)

#### ក. គោលការណ៍នៃការផ្តល់សេវា

ជលយានប្រភេទដឹកទំនិញ ដឹកអ្នកដំណើរ សាឡង់ដឹកទំនិញ(គ្មានម៉ាស៊ីន) នេសាទ និងសណ្តោងរុញដែលធ្វើចរាចរតាមផ្លូវទឹកនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានបណ្ណសម្គាល់ជលយាន។ ការផ្តល់បណ្ណសម្គាល់ជលយានត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ម្ចាស់ជលយានត្រូវដាក់ពាក្យស្នើសុំបណ្ណសម្គាល់ជលយានក្នុងរយៈពេល១ខែ ចំពោះជលយាន ដែលទិញ ឬសាងសង់រួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងរយៈពេល២ខែ ចំពោះ ជលយានដែលនាំចូលពីបរទេសគិតចាប់ពីថ្ងៃបង់ពន្ធរួច
- រយៈពេលអតិបរមា និងកម្រៃសេវានៃការផ្តល់បណ្ណសម្គាល់ជលយានត្រូវអនុវត្តតាមគោលការណ៍ កំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បណ្ណសម្គាល់ជលយានមានសុពលភាពអចិន្ត្រៃយ៍។

## ខ. បែបបទ និងនីតិវិធី

ម្ចាស់ជលយានដែលមានបំណងស្នើសុំបណ្ណសម្គាល់ជលយានប្រភេទដឹកទំនិញ ដឹកអ្នកដំណើរ សាឡង់ដឹកទំនិញ(គ្មានម៉ាស៊ីន) នេសាទ និងសណ្តោង/រុញ ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។

### ខ.១.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ការស្នើសុំបណ្ណសម្គាល់ជលយានដែលមានចំណុះផ្ទុកពី៤០តោនចុះក្រោម ពី៥០កៅអីចុះក្រោម និង កម្លាំងម៉ាស៊ីនពី៩០សេះចុះក្រោម ត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១- ពាក្យស្នើសុំបណ្ណសម្គាល់ជលយាន

២- លិខិតទិញលក់ ឬលិខិតសាងសង់

៣- អត្តសញ្ញាណម្ចាស់ជលយាន

- នីតិបុគ្គល (ក្រុមហ៊ុន ឬសហកម្មសិទ្ធិ)៖ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងបណ្ណ ប៉ាតង់ (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច)
- រូបវន្តបុគ្គល៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីស្ថាប័ន មានសមត្ថកិច្ច)

៤-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីសាមីខ្លួនមាន អាសយដ្ឋានខុសពីអត្តសញ្ញាណប័ណ្ណ)

៥- ប្លង់សាងសង់

៦- បង្កាន់ដៃពន្ធ (សម្រាប់ជលយាននាំចូល)

*ទម្រង់ពាក្យស្នើសុំសេវាផ្តល់បណ្ណសម្គាល់ជលយាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។*

### ខ.២ នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ ម្ចាស់ជលយានត្រូវ មកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូល តែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូល តែមួយ ដើម្បីកំណត់កាលបរិច្ឆេទចុះទៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន
- បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យ វាយតម្លៃ និងផ្តល់យោបល់បច្ចេកទេសលើការស្នើសុំបណ្ណ សម្គាល់ជលយានផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ " កំណត់បង្ហាញរឿង " ដោយផ្តល់យោបល់បច្ចេកទេសលើ

សេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងបណ្ណសម្គាល់ជលយាន ឬលិខិតឆ្លើយតប រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ

- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងបណ្ណសម្គាល់ជលយាន ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

***កំណត់សម្គាល់៖*** *ការបែងចែកចង្កោមលេខ និងអក្សរដើមនៃផ្លាកលេខ ឈ្មោះជលយាន ត្រូវអនុវត្តតាមការកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំនេះ។*

## ១.២. ការប្តូរម៉ាស៊ីន ពណ៌ កែមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន

### ១.២.១. ការប្តូរម៉ាស៊ីន ពណ៌ កែមាឌ

#### ក. គោលការណ៍នៃការផ្តល់សេវា

ការស្នើសុំប្តូរម៉ាស៊ីន ពណ៌ កែមាឌត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ការស្នើសុំប្តូរម៉ាស៊ីន ពណ៌ កែមាឌ ម្ចាស់ជលយានត្រូវដាក់ពាក្យស្នើសុំបណ្ណសម្គាល់ជលយានសារជាថ្មី។ ក្នុងករណីនេះ ផ្លាកសម្គាល់ជលយានត្រូវរក្សាទុកដដែល ដោយគ្រាន់តែធ្វើការកែតម្រូវក្នុងបញ្ជីគ្រប់គ្រងជលយានតែប៉ុណ្ណោះ
- រយៈពេលអតិបរមា និងកម្រៃសេវានៃការផ្តល់បណ្ណសម្គាល់ជលយានត្រូវអនុវត្តតាមគោលការណ៍កំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។

#### ខ. បែបបទ និងនីតិវិធី

ម្ចាស់ជលយានដែលមានបំណងស្នើសុំប្តូរម៉ាស៊ីន ពណ៌ កែមាឌត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។

#### ខ.១. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ការស្នើសុំប្តូរម៉ាស៊ីនជលយាន ពណ៌ កែមាឌត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យស្នើសុំ

២-បណ្ណសម្គាល់ជលយានចាស់

៣-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

៤-លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក (សម្រាប់ការធ្វើអាជីវកម្ម)

៥-ប្លង់កែច្នៃ

*ទម្រង់ពាក្យស្នើសុំប្តូរម៉ាស៊ីន ពណ៌ កែមាឌ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។*

#### ខ.២. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ ម្ចាស់ជលយានត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយ ដើម្បីកំណត់កាលបរិច្ឆេទ ចុះទៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

- បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យវាយតម្លៃ និងផ្តល់យោបល់បច្ចេកទេសលើការស្នើសុំប្តូរម៉ាស៊ីន ជលយាន ពណ៌ កែមាឌ ផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងបណ្ណសម្គាល់ជលយាន ឬលិខិតឆ្លើយតប រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងបណ្ណសម្គាល់ជលយាន ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

### ១.២.២. ការផ្ទេរម្ចាស់កម្មសិទ្ធិជលយាន

### ក. គោលការណ៍នៃការផ្តល់សេវា

ការផ្ទេរម្ចាស់កម្មសិទ្ធិជលយាន ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ការស្នើសុំផ្ទេរម្ចាស់កម្មសិទ្ធិជលយាន ម្ចាស់ជលយានត្រូវដាក់ពាក្យស្នើសុំបណ្ណសម្គាល់ជលយានសារជាថ្មី
- ផ្លាកលេខសម្គាល់ជលយានត្រូវរក្សាទុកដដែល ចំពោះការផ្ទេរកម្មសិទ្ធិជលយានដែលម្ចាស់កម្មសិទ្ធិថ្មីមានអាសយដ្ឋាននៅក្នុងរាជធានី ខេត្តតែមួយជាមួយម្ចាស់ជលយានចាស់។ ក្នុងករណីម្ចាស់កម្មសិទ្ធិថ្មីមានអាសយដ្ឋាននៅក្នុងរាជធានី ខេត្ត ខុសពីម្ចាស់កម្មសិទ្ធិជលយានចាស់ ផ្លាកលេខសម្គាល់ជលយាននឹងត្រូវផ្លាស់ប្តូរថ្មី
- រយៈពេលអតិបរមា និងកម្រៃសេវានៃការផ្តល់បណ្ណសម្គាល់ជលយានត្រូវអនុវត្តតាមគោលការណ៍កំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ខ. បែបបទ និងនីតិវិធី

ម្ចាស់ជលយានដែលមានបំណងស្នើសុំផ្ទេរម្ចាស់កម្មសិទ្ធិជលយាន ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តដែលជលយានតាំងនៅ។

### ខ.១.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ការស្នើសុំផ្ទេរម្ចាស់កម្មសិទ្ធិជលយានត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យស្នើសុំ

២-លិខិតលក់ទិញ

៣-អត្តសញ្ញាណម្ចាស់ជលយាន (អ្នកលក់ និងអ្នកទិញ)

- នីតិបុគ្គល (ក្រុមហ៊ុន ឬសហកម្មសិទ្ធិ)៖ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងបណ្ណប៉ាតង់ (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច)
- រូបវន្តបុគ្គល៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច)

៤-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីសាមីខ្លួនមានអាសយដ្ឋានខុសពីអត្តសញ្ញាណប័ណ្ណ)

៥-បណ្ណសម្គាល់ជលយានចាស់

៦-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

៧-លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក (សម្រាប់ការធ្វើអាជីវកម្ម)

៨-បង្កាន់ដៃបង់ពន្ធប្រថាប់ត្រា

*ទម្រង់ពាក្យស្នើសុំផ្ទេរម្ចាស់កម្មសិទ្ធិជលយាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។*

### គ. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ ម្ចាស់ជលយានត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលអ្នកទិញជលយាននោះតាំងនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំពីម្ចាស់ជលយាន បុគ្គលិកផ្នែកជួរក្រោយត្រូវកំណត់កាលបរិច្ឆេទដើម្បីចុះទៅពិនិត្យ វាយតម្លៃ និងផ្តល់យោបល់បច្ចេកទេសលើការស្នើសុំផ្ទេរកម្មសិទ្ធិជលយានផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយអញ្ជើញភាគីអ្នកលក់ និងអ្នកទិញមកផ្តិតមេដៃនៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច
- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ " កំណត់បង្ហាញរឿង" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតឆ្លើយតប រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

## ១.៣. ការប្តូរ(ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន

### ក. គោលការណ៍នៃការផ្តល់សេវា

ការប្តូរ (ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយានត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ម្ចាស់កម្មសិទ្ធិត្រូវដាក់ពាក្យសុំប្តូរ (ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ក្នុងករណីបណ្ណសម្គាល់ជលយានមានការខូចខាត ឬបាត់បង់ដោយប្រការណាមួយ។ ក្នុងករណីនេះ ផ្លាកសម្គាល់ជលយានត្រូវរក្សាទុកដដែល ដោយគ្រាន់តែធ្វើការកែតម្រូវក្នុងបញ្ជីគ្រប់គ្រងជលយានតែប៉ុណ្ណោះ
- រយៈពេលអតិបរមា និងកម្រៃសេវានៃការផ្តល់បណ្ណសម្គាល់ជលយានត្រូវអនុវត្តតាមគោលការណ៍កំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ខ. បែបបទ និងនីតិវិធី

ម្ចាស់ជលយានដែលមានបំណងប្តូរ (ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។

៥

### ខ.១. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ការស្នើសុំប្តូរ (ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយានត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

១-ពាក្យស្នើសុំ

២-អត្តសញ្ញាណម្ចាស់ជលយាន

- នីតិបុគ្គល (ក្រុមហ៊ុន ឬសហកម្មសិទ្ធិ)៖ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងបណ្ណប៉ាតង់(ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច)
- រូបវន្តបុគ្គល៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងដែលមានបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច)

៣-សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ (ក្នុងករណីសាមីខ្លួនមានអាសយដ្ឋានខុសពីអត្តសញ្ញាណប័ណ្ណ)

៤-ពាក្យបណ្តឹងពីអាជ្ញាធរមានសមត្ថកិច្ច (ក្នុងករណីបាត់បណ្ណសម្គាល់ជលយាន)

៥-បណ្ណសម្គាល់ជលយានដែលខូច

*ទម្រង់ពាក្យស្នើសុំប្តូរ (ការប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយានមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។*

### គ. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ ម្ចាស់ជលយានត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលជលយានបានចុះបញ្ជី។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យលើពាក្យស្នើសុំប្តូរ ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន
- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន ឬលិខិតឆ្លើយតប រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងបណ្ណសម្គាល់ជលយាន ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

## ១.៤. ការគ្រប់គ្រង

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំឲ្យមានសម្រង់ព័ត៌មានអំពីការផ្តល់បណ្ណសម្គាល់ជលយាន ការស្នើសុំប្តូរម៉ាស៊ីន ពណ៌ កែមាឌ ឬផ្ទេរម្ចាស់កម្មសិទ្ធិជលយាន និងការស្នើសុំប្តូរ ឬទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយានរបស់ម្ចាស់ជលយាននៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនិងការអនុវត្ត ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ សម្រង់ព័ត៌មាននេះត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិច១ឆ្នាំម្តង។

## ២. ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ត្រូវផ្តល់សេវាលើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ដែលមានចំណុះផ្ទុកពី៤០តោនចុះក្រោម ផ្ទុកអ្នកដំណើរពី៥០នាក់ចុះក្រោម និងកម្លាំងពី៩០សេះចុះក្រោម។

### ២.១.ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន(ចំណុះផ្ទុកពី៤០តោនចុះក្រោម ផ្ទុកអ្នកដំណើរពី៥០កៅអីចុះក្រោម និងកម្លាំងម៉ាស៊ីនពី៩០សេះចុះក្រោម)

### ក. គោលការណ៍នៃការផ្តល់សេវា

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានដែលមានចំណុះផ្ទុកពី៤០តោនចុះក្រោម ផ្ទុកអ្នកដំណើរពី៥០នាក់ចុះក្រោម និងកម្លាំងពី៩០សេះចុះក្រោម ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- គ្រប់ជលយានដែលធ្វើចរាចរលើផ្ទៃទឹកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ចេញដោយរដ្ឋបាលរាជធានី ខេត្ត
- សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានមានសុពលភាពរយៈពេល១ឆ្នាំ
- រយៈពេលអតិបរមា និងកម្រៃសេវានៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសត្រូវអនុវត្តតាមគោលការណ៍កំណត់នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ខ. បែបបទ និងនីតិវិធី

ម្ចាស់ជលយានដែលមានបំណងត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានដែលមានចំណុះផ្ទុកពី៤០តោនចុះក្រោម ផ្ទុកអ្នកដំណើរពី៥០នាក់ចុះក្រោម និងកម្លាំងពី៩០សេះចុះក្រោម ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។

### ខ.១.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ម្ចាស់ជលយានដែលមានបំណងត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ត្រូវមកទទួលពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

១-ពាក្យស្នើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

២-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

៣-បណ្ណសម្គាល់ជលយាន។

*ទម្រង់ពាក្យស្នើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។*

### ខ.២. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ម្ចាស់ជលយានត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលបានផ្តល់បណ្ណសម្គាល់ជលយាននោះ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយដើម្បីកំណត់កាលបរិច្ឆេទចុះទៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានដល់ទីតាំង

៦

- បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យ វាយតម្លៃ និងផ្តល់យោបល់បច្ចេកទេសលើការស្នើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ផ្អែកលើលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ឬលិខិតឆ្លើយតប រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

**២.២. ការគ្រប់គ្រង**

រដ្ឋបាលរាជធានី-ខេត្តត្រូវរៀបចំឲ្យមានសម្រង់ព័ត៌មានអំពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានរបស់ម្ចាស់ជលយាននៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ សម្រង់ព័ត៌មាននេះត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិច ១ឆ្នាំម្តង។

**៣. ការផ្តល់លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក (ចំណុះផ្ទុកពី៤០តោនចុះក្រោម ផ្ទុកអ្នកដំណើរពី៥០នាក់ចុះក្រោម និងកម្លាំងម៉ាស៊ីនពី៩០សេះចុះក្រោម)**

អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ត្រូវផ្តល់សេវាលើការផ្តល់លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក រួមមាន៖ នាវាដឹកទំនិញ សាឡង់ដឹកទំនិញ (គ្មានម៉ាស៊ីន) នាវាដឹកអ្នកដំណើរ និងនាវាសណ្តោង/រុញ។

**ក. គោលការណ៍នៃការផ្តល់សេវា**

ការផ្តល់លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹកចំពោះ នាវាដឹកទំនិញ សាឡង់ដឹកទំនិញ (គ្មានម៉ាស៊ីន) នាវាដឹកអ្នកដំណើរ និងនាវាសណ្តោង/រុញ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖
- គ្រប់ជលយានធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ចេញដោយរដ្ឋបាលរាជធានី ខេត្ត
- លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក មានសុពលភាពរយៈពេល១ឆ្នាំ
- រយៈពេលអតិបរមា និងកម្រៃសេវានៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសត្រូវអនុវត្តតាមគោលការណ៍កំណត់ នៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ខ. បែបបទ និងនីតិវិធី**

ម្ចាស់ជលយានដែលមានបំណងធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹករួមមាន៖ នាវាដឹកទំនិញ សាឡង់ដឹកទំនិញ(គ្មានម៉ាស៊ីន) នាវាដឹកអ្នកដំណើរ និងនាវាសណ្តោង/រុញ ត្រូវដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលទីតាំងជលយាននោះតាំងនៅ។

**ខ.១. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

ម្ចាស់ជលយានដែលមានបំណងស្នើសុំលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ត្រូវមកទទួលពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

១-ពាក្យស្នើសុំ

២-បណ្ណសម្គាល់ជលយាន

៣-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានដែលមានសុពលភាព

៤-លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹកចាស់ (បន្តសុពលភាព)។

*ទម្រង់ពាក្យស្នើសុំលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ។*

### ខ.២. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ ម្ចាស់ជលយានត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី-ខេត្ត ដែលជលយានកំពុងធ្វើអាជីវកម្ម។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយត្រូវពិនិត្យលើពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក
- បុគ្គលិកផ្នែកជួរក្រោយត្រូវរៀបចំ "កំណត់បង្ហាញរឿង" ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ ព្រមទាំង រៀបចំសេចក្តីព្រាងលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ឬលិខិតឆ្លើយតប រួចបញ្ជូនទៅប្រធានអង្គភាពច្រកចេញចូលតែមួយ
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

### ៣.១. ការគ្រប់គ្រង

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំឲ្យមានសម្រង់ព័ត៌មានអំពីការផ្តល់លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក ដូចជា៖ ការផ្តល់លិខិតអនុញ្ញាតអាជីវកម្មនាវាដឹកទំនិញ ការផ្តល់លិខិតអនុញ្ញាតអាជីវកម្មសាឡង់ដឹកទំនិញ (គ្មានម៉ាស៊ីន) ការផ្តល់លិខិតអនុញ្ញាតអាជីវកម្មនាវាដឹកអ្នកដំណើរ និងការផ្តល់លិខិតអនុញ្ញាតអាជីវកម្មនាវាសណ្តោង/រុញរបស់ម្ចាស់ជលយាននៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងការអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ សម្រង់ព័ត៌មាននេះត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិច១ឆ្នាំម្តង។

## ៤. កម្រៃសេវា និងសុពលភាព

កម្រៃសេវាសាធារណៈ និងសុពលភាពនៃបណ្ណសម្គាល់ជលយាន ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងការផ្តល់លិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក សម្រាប់ការស្នើសុំសេវាខាងលើ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពនូវការផ្តល់សេវាសាធារណៈស្របតាមបែបបទនិងនីតិវិធី និងរយៈពេលនៃការផ្តល់សេវាដូចមានកំណត់ក្នុងប្រកាសរួមរវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៥. របាយការណ៍

រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីការផ្តល់បណ្ណសម្គាល់ជលយាន ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន និងការចេញលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក មកក្រសួងសាធារណការ និងដឹកជញ្ជូន ដោយចម្លងជូនក្រសួងមហាផ្ទៃ តាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋបាលរាជធានី ខេត្តត្រូវអនុវត្តតាមខ្លឹមសារខាងលើឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ.........ខែ.........ឆ្នាំជូត ទោស័ក .ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

- ពាក្យស្នើសុំបណ្ណសម្គាល់ជលយាន
- ពាក្យស្នើសុំប្តូរ (ប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន
- ពាក្យស្នើសុំអនុញ្ញាតប្តូរម៉ាស៊ីន ប្តូរពណ៌ កែមាឌ និងប្តូរម្ចាស់កម្មសិទ្ធិ
- ពាក្យស្នើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន
- ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក
- បណ្ណសម្គាល់នាវា
- សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន
- លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំបណ្ណសម្គាល់ជលយាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.................................ភេទ..............អាយុ.............ឆ្នាំ ជនជាតិ..................
សញ្ជាតិ................មុខរបរសព្វថ្ងៃ....................................ទីលំនៅបច្ចុប្បន្នផ្ទះលេខ......................
ផ្លូវលេខ..........................ភូមិ.......................................ឃុំ-សង្កាត់......................................
ក្រុង-ស្រុក-ខណ្ឌ.......................................... រាជធានី-ខេត្ត...............................................
អត្តសញ្ញាណប័ណ្ណលេខ....................................ទូរស័ព្ទលេខ..........................................។

**សូមគោរពជូន**
**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**..............................

**<u>កម្មវត្ថុ</u>**៖ សំណើសុំបណ្ណសម្គាល់ជលយាន។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាជ្រាបថា ដោយខ្ញុំបាទ-នាងខ្ញុំទើបនឹងទិញ ឬសាងសង់................................................ ដែលពុំទាន់មានបណ្ណសម្គាល់នៅឡើយ ហើយដែលមានកិនភាគដូចខាងក្រោម៖

- ឈ្មោះជលយាន...................................... ម៉ាកម៉ាស៊ីន..........................................
- ប្រភេទជលយាន.................................. លេខម៉ាស៊ីន..........................................
- បណ្ដោយ.........................................ម៉ែត្រ កម្លាំងម៉ាស៊ីន..............................សេះ
- ទទឹង...............................................ម៉ែត្រ ចំនួនជុំ...................................................
- កម្ពស់ពីទឹកដល់ដំបូល.........................ម៉ែត្រ សំបក..................ពណ៌.................
- កម្ពស់ពីទឹកដល់ដងម៉ា.........................ម៉ែត្រ ចំនួនអ្នកដំណើរ....................................
- ជំរៅទឹកមិនទាន់ផ្ទុក............................ម៉ែត្រ ជំរៅទឹកផ្ទុកពេញ......................................
- ទម្ងន់ផ្ទុកទំនិញ...................................តោន ទម្ងន់សរុប..............................តោន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាអនុញ្ញាត ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ......................ខែ.............ឆ្នាំ..........ព.ស...........
ធ្វើនៅ............... ថ្ងៃទី..........ខែ............ឆ្នាំ...........
**ស្នាមមេដៃស្ដាំ**

**<u>ជូនភ្ជាប់មកជាមួយ៖</u>**

- អត្តសញ្ញាណប័ណ្ណ (ច្បាប់ថតចម្លង) ១ច្បាប់
- បណ្ណស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ (អាសយដ្ឋានបច្ចុប្បន្នខុសពីអត្តសញ្ញាណប័ណ្ណ) (ច្បាប់ថតចម្លង) ១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ករណីក្រុមហ៊ុន) (ច្បាប់ថតចម្លង) ១ច្បាប់
- លិខិតទិញលក់ ឬសាងសង់ (ច្បាប់ដើម) ១ច្បាប់
- ប្លង់សាងសង់ (ច្បាប់ដើម) ១ច្បាប់
- បង្កាន់ដៃពន្ធនាំចូល (ច្បាប់ដើម)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................ភេទ...............អាយុ................ឆ្នាំ ជនជាតិ.................
សញ្ជាតិ.................មុខរបរសព្វថ្ងៃ..................................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................
ផ្លូវលេខ............................... ភូមិ...................................ឃុំ-សង្កាត់............................................
ក្រុង-ស្រុក-ខណ្ឌ...................................................រាជធានី-ខេត្ត.................................................
អត្តសញ្ញាណប័ណ្ណ...................................................ទូរស័ព្ទលេខ............................................។

**សូមគោរពជូន**
**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត..........................**

**<u>កម្មវត្ថុ</u>**៖ សំណើសុំប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយាន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាជ្រាបថា ខ្ញុំបាទ-នាងខ្ញុំសុំប្តូរ(ប្តូរឈ្មោះជលយាន) ទុតិយតា ឬតតិយតាបណ្ណសម្គាល់ជលយានដែលមានភិនភាគ ដូចខាងក្រោម៖

- ឈ្មោះជលយាន......................បណ្ណសម្គាល់លេខ......................ម៉ាកម៉ាស៊ីន...............
- ប្រភេទជលយាន.................................. លេខម៉ាស៊ីន.......................................
- បណ្តោយ...........................................ម៉ែត្រ កម្លាំងសេះ.........................................
- ទទឹង...............................................ម៉ែត្រ ចំនួនជុំ..............................................
- កម្ពស់ពីទឹកដល់ដំបូល.........................ម៉ែត្រ សំបក.................ពណ៌.....................
- កម្ពស់ពីទឹកដល់ដងម៉ា.........................ម៉ែត្រ ចំនួនអ្នកដំណើរ...................................
- ជំរៅទឹកគ្មានទំនិញ...............................ម៉ែត្រ ជំរៅទឹកផ្ទុកពេញ.................................
- ទម្ងន់ផ្ទុកទំនិញ...................................តោន ទម្ងន់សរុប...............................តោន

មូលហេតុ.......................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាអនុញ្ញាតដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ......................ខែ.................ឆ្នាំ..........ព.ស...........
ធ្វើនៅ................ ថ្ងៃទី.......... ខែ...........ឆ្នាំ..........

**ស្នាមមេដៃស្តាំ**

**<u>ជូនភ្ជាប់មកជាមួយ៖</u>**

- អត្តសញ្ញាណប័ណ្ណ (ច្បាប់ថតចម្លង) ១ច្បាប់
- បណ្ណស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅ (អាសយដ្ឋានបច្ចុប្បន្នខុសពីអត្តសញ្ញាណប័ណ្ណ)(ច្បាប់ថតចម្លង) ១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ១ច្បាប់
- បណ្ណសម្គាល់ជលយានចាស់ (ច្បាប់ដើម) ១ច្បាប់
- ពាក្យបណ្តឹងពីអាជ្ញាធរមានសមត្ថកិច្ច (ច្បាប់ដើម) ១ច្បាប់

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..........................................................ភេទ...............អាយុ..............ឆ្នាំ
ជនជាតិ.........សញ្ជាតិ.........មុខរបរសព្វថ្ងៃ......................ទីលំនៅបច្ចុប្បន្នផ្ទះលេខ......................
ផ្លូវលេខ.......................ភូមិ..........................................ឃុំ-សង្កាត់.........................................
ក្រុង-ស្រុក-ខណ្ឌ...................................រាជធានី-ខេត្ត..........................................................
អត្តសញ្ញាណប័ណ្ណលេខ................................................ទូរស័ព្ទលេខ...............................។

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**...............................

**<u>កម្មវត្ថុ</u>៖** សំណើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំបាទ-នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាជ្រាបថាខ្ញុំបាទ-នាងខ្ញុំ ស្នើសុំធ្វើការត្រួតពិនិត្យជលយាន □ ថ្មី □ បន្ត ដែលមានកិនភាគដូចខាងក្រោម៖

- ឈ្មោះជលយាន.................................. - បណ្ណសម្គាល់..................................
- ប្រភេទជលយាន.................................. - ម៉ាកម៉ាស៊ីន..................................
- បណ្តោយ.................................. - លេខម៉ាស៊ីន..................................
- ទទឹង.................................. - កម្លាំងសេះ ..................................
- កម្ពស់ពីទឹកដល់ដំបូល.................................. - ចំនួនជុំ..................................
- កម្ពស់ពីទឹកដល់ដងម៉ា.................................. - ប្រភេទសំបក..................................
- ទម្ងន់ផ្ទុកទំនិញ.................................. - ចំនួនអ្នកដំណើរ..................................

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាចាត់មន្ត្រីមានជំនាញបច្ចេកទេសចុះត្រួតពិនិត្យជលយានរបស់ខ្ញុំបាទ-នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ..............................ខែ................ឆ្នាំ..........ព.ស...........
ធ្វើនៅ............... ថ្ងៃទី........ខែ...........ឆ្នាំ............
**ស្នាមមេដៃស្តាំ**

**<u>ជូនភ្ជាប់មកជាមួយ៖</u>**

-បណ្ណសម្គាល់ជលយាន (ថតចម្លង) ១ច្បាប់
-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជនយាន (បន្ត) ១ច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវទឹក

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.............................................ភេទ...................អាយុ.........................ឆ្នាំ
ជនជាតិ............សញ្ជាតិ........... មុខរបរសព្វថ្ងៃ....................ទីលំនៅបច្ចុប្បន្នផ្ទះលេខ..................
ផ្លូវលេខ......................ភូមិ............................................ ឃុំ-សង្កាត់..........................................
ក្រុង-ស្រុក-ខណ្ឌ..........................................រាជធានី-ខេត្ត..................................................
អត្តសញ្ញាណប័ណ្ណលេខ...............................................ទូរស័ព្ទលេខ..........................................។

**សូមគោរពជូន**
**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**..............................

**កម្មវត្ថុ៖** សំណើសុំលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូនផ្លូវទឹក៖

☐ នាវាដឹកទំនិញ ☐ សាឡង់ដឹកទំនិញ (គ្មានម៉ាស៊ីន)
☐ នាវាដឹកអ្នកដំណើរ ☐ នាវាសណ្តោង/រុញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាជ្រាបថា ដោយខ្ញុំបាទ-នាងខ្ញុំ....................................ចំនួន..........គ្រឿង ដែលមានកិនភាគដូចខាងក្រោម៖

- ឈ្មោះជលយាន.........................................បណ្ណសម្គាល់នាវា................................
- ប្រភេទជលយាន.......................................បណ្តោយ.............................................
- ម៉ាកម៉ាស៊ីន..............................................ទទឹង...................................................
- លេខម៉ាស៊ីន..............................................កម្លាំងសេះ.........................................
- កម្ពស់ពីទឹកដល់ដំបូល...............................កម្ពស់ពីទឹកដល់ដងម៉ា..............................
- ទម្ងន់ផ្ទុកទំនិញ.........................................ចំណុះផ្ទុកអ្នកដំណើរ.............................
- ប្រភេទសំបក.........................ពណ៌..................................ចំនួនជុំ.........................
- ទិសដៅ...........................................................ទម្ងន់សរុប.................................

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាអនុញ្ញាតឲ្យខ្ញុំបាទ-នាងខ្ញុំ........ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម លោកជំទាវអភិបាល** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ..............................ខែ..................ឆ្នាំ..........ព.ស...........
ធ្វើនៅ............ ថ្ងៃទី..........ខែ............ឆ្នាំ...........
**ស្នាមមេដៃស្តាំ**

**ជូនភ្ជាប់មកជាមួយ៖**

- បណ្ណសម្គាល់ជលយាន (ថតចម្លង) ១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ថតចម្លង) ១ច្បាប់
- សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយាន (ថតចម្លង) ១ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មចាស់ (ករណីបន្តសុពលភាព) ១ច្បាប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA
NATION RELIGION KING

រដ្ឋបាលរាជធានី ខេត្ត..................
CAPITAL PROVINCIAL ADMINISTRATION
អង្គភាពច្រកចេញចូលតែមួយ
ONE WINDOW SERVICE UNIT

# បណ្ណសម្គាល់នាវា
# SHIP'S CARD

លេខ..............................
Nº..................................

## ម្ចាស់កម្មសិទ្ធិ

SHIP OWNER

